ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ចំណាត់ការលើសំណុំរឿងវិវាទការងារ

អនុលោមតាមច្បាប់ស្តីពីការងារ បន្ទាប់ពីបានទទួលនូវបណ្តឹងអំពីវិវាទការងារ អ្នកផ្សះផ្សានៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចាត់វិធានការភ្លាមៗ ដោយចាប់ផ្តើមធ្វើការផ្សះផ្សាស្របតាមនីតិវិធីច្បាប់ជាធរមាន។ ក្នុងន័យនេះ ដើម្បីធានាបាននូវការដោះស្រាយវិវាទការងារប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីភាគីវិវាទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងទៅភាគីវិវាទនៃសំណុំរឿងវិវាទការងារ ដែលមិនមានឆន្ទៈចូលរួមដោះស្រាយ ត្រូវតែចូលរួមក្នុងយន្តការផ្សះផ្សា និងដោះស្រាយបញ្ចប់វិវាទការងារ ឱ្យបានមុនថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ មានរាយនាមដូចខាងក្រោម៖

១- ក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ថិកស្ទាយ៍ (Zhong Yin (Cambodia) B Textile Co., Ltd.)
២- ក្រុមហ៊ុន អេវើហ្គ្រីន អ៊ិនដាស្ទ្រៀល ខូ អិលធីឌី (Evergreen Industrial Co., Ltd.)
៣- ក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប (H C C Group Co., Ltd.)
៤- ក្រុមហ៊ុន អេ ហ្សេត អាយ អ៊ី&ស៊ី ឯ.ក (A Z I E&C COMPANY LIMITED)
៥- ក្រុមហ៊ុន សេហាន ហ្វើនីឈ័រ & អ៊ិនធៀរៀ ឯ.ក (Saehan Furniture & Interior Co., Ltd.)។

ក្នុងករណីភាគីវិវាទមិនអនុវត្តតាមចំណាត់ការខាងលើ អធិការការងារនឹងចាត់វិធានការបន្តលើសំណុំរឿងវិវាទការងារទាំងនេះ និងបន្តសហការរៀបចំសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ ភាគីវិវាទដែលជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ព្រមទាំងតំណាងរបស់ភាគីវិវាទត្រូវចូលរួមដោះស្រាយបញ្ចប់វិវាទការងារខាងលើដោយស្មារតីទទួលខុសត្រូវ និងមិនត្រូវអូសបន្លាយពេលវេលាក្នុងការដោះស្រាយបញ្ចប់វិវាទការងារ ដែលនាំឱ្យប៉ះពាល់ដល់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈនោះទេ។

សូម ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត សហជីព សមាគមនិយោជក និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩